អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១៦

# សេចក្តីប្រកាសព័ត៌មាន
# សាលដីកាស្ថាពរលើបណ្តឹងសាទុក្ខ
# ក្នុងសំណុំរឿង ០០២/០១ នឹងត្រូវប្រកាសនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦

អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានជូនដំណឹងថាខ្លួននឹងប្រកាសសាលដីកាស្ថាពរលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ប្រឆាំងនឹង នួន ជា និងខៀវ សំផន នៅថ្ងៃពុធ ទី២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦ វេលាម៉ោង ៩ ព្រឹកនៅក្នុងសាលសវនាការរបស់ អ.វ.ត.ក។

សំណុំរឿង ០០២/០១ គឺជាការជំនុំជម្រះលើកទីមួយនៃការជំនុំជម្រះយ៉ាងតិចពីរ ប្រឆាំងនឹង នួន ជា អតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងខៀវ សំផន អតីតប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ។ បទចោទនៅក្នុងសំណុំរឿង ០០២/០១ នេះគឺផ្តោតលើបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលរងការចោទប្រកាន់ក្នុងអំឡុងពេលជម្លៀសប្រជាជននៅទីក្រុងភ្នំពេញ ក្នុងខែមេសា ឆ្នាំ ១៩៧៥ និងការផ្លាស់ទីដោយបង្ខំបន្តបន្ទាប់ពីតំបន់ដទៃទៀត រួមទាំងការកាប់សម្លាប់ដែលរងការចោទប្រកាន់នៅទួលពោធិ៍ជ្រៃ ក្នុងខេត្តពោធិ៍សាត់។ នៅថ្ងៃទី ៧ ខែ សីហា ២០១៤ អង្គជំនុំជម្រះសាលាដំបូង រកឃើញថា ជនជាប់ចោទមានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបានសម្រេចប្រកាសទោសដាក់ពន្ធនាគារជនជាប់ចោទទាំងពីរអស់មួយជីវិត។ នួន ជា និង ខៀវ សំផន បានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយម្នាក់ៗបានលើកទឡ្ហីករណ៍បណ្តឹងសាទុក្ខរៀងៗខ្លួនចំនួន ២២៣ និង ១៤៨។ បន្ថែមលើនេះ សហព្រះរាជអាជ្ញា បានដាក់បណ្តឹងសាទុក្ខ ដោយកម្រិតត្រឹមតែស្វែងរកដំណោះស្រាយដែលប្រកាសដោយអង្គជំនុំជម្រះតុលាការកំពូល ទាក់ទងនឹងភាពអាចអនុវត្តបាននូវទម្រង់ពង្រីកបន្ថែមនៃសហឧក្រិដ្ឋកម្មរួម ដែលហៅថា “សហឧក្រិដ្ឋកម្មរួមទម្រង់ទី III” (JCE III) នៅចំពោះមុខ អ.វ.ត.ក។

ព័ត៌មានអំពីការចូលរួមរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងការបែងចែកកន្លែងអង្គុយនៅក្នុងសាលសវនាការសាធារណៈនឹងត្រូវជូនដំណឹងនៅអនាគតដ៏ខ្លីខាងមុខ។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

**លោក ឡាស អូលសិន**

មន្រ្តីផ្នែកច្បាប់

ទូរស័ព្ទចល័តៈ +៨៥៥ (0) ១២ ៤៨៨ ០២៣

ទូរស័ព្ទៈ +៨៨៥ (0) ២៣ ៨៦១ ៦៦៩

សារអេឡិកត្រូនិកៈ olsenl@un.org

**លោក នេត្រ ភក្ត្រា**

មន្រ្តីនាំពាក្យសាលាក្តីខ្មែរក្រហម

ទូរស័ព្ទចល័តៈ +៨៥៥ (0) ១២ ៤៨៨ ១៥៦

ទូរស័ព្ទៈ +៨៨៥ (0) ២៣ ៨៦១ ៥៦៤

សារអេឡិចត្រូនិកៈ neth.pheaktra@eccc.gov.kh



**www.eccc.gov.kh**